# សុរាបានកថា

www.elibraryofcambodia.org

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥១៣

www.elibraryofcambodia.org

# សុវារធាសកថា

ព្រះវិសុទ្ធិវង្ស ហ~តាត អាចារ្យបង្រៀនសំស្ក្រឹត

នៅសាលាបរិយត្តិជាន់ខ្ពស់ ភ្នំពេញ រៀបរៀង

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយក

ទាំងពីរគណៈ បានអនុញ្ញាតហើយ

បោះពុម្ពលើកទី ៤

www.elibraryofcambodia.org

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥១៣

www.elibraryofcambodia.org

# SURĀDOSAKATHĀ

ou

# LES MEFAITS DE L'ALCOOL

par

Préah Visuddhivong H. Tath
Professeur de Sanscrit
à l'École Supérieure de palī
à Phnom-Penh

Cette publication a reçu l'approbation
du conseil des ministres et des deux chefs de secte

Cinquiéme Édition

www.elibraryofcambodia.org

PHNOM - PENH
Édition de l'Institut Bouddhique
1969

www.elibraryofcambodia.org

# សម្តែងអំពីទោសនៃការផឹកស្រា

www.elibraryofcambodia.org

ជនប្រុសស្រីទាំងឡាយ ដែលកើតមកក្នុងលោកនេះ បើចង់ឲ្យបានសេចក្តីសុខសេចក្តីចម្រើនដល់ខ្លួន គួរតែចៀសវាងអំពីការផឹកស្រាឲ្យផុត បើទុកជាធ្លាប់ផឹកជាប់តែមកហើយក្តី ក៏ត្រូវតែប្រញាប់ប្រញាល់ឈប់លែងផឹកឲ្យស្រឡះចេញ ឬក៏ផឹកនោះមិនជាប់ជានិច្ចទេ យូរៗ ផឹក

ម្ដងក្ដី ក៏ត្រូវតែផ្ដាច់ការផឹកនោះចេញ ដើម្បីកុំឲ្យជាទម្លាប់ ព្រោះសុរានេះជាគ្រឿងពិសពុល មិននាំឲ្យកើតសេចក្ដីសុខស្រួលឬនាំឲ្យកើតសេចក្ដីចម្រើនដល់អ្នកផឹកណាមួយឡើយ មានតែនាំបំផ្លាញអ្នកផឹក ឲ្យបានសេចក្ដីវិនាសច្រើនយ៉ាង មានវិនាសទ្រព្យសម្បត្តិនិងវិនាសសតិបញ្ញា ជាដើម ។

ក្នុងសិង្គាលោវាទសូត្រ គម្ពីរទីឃនិកាយ បាដិកវគ្គ

www.elibraryofcambodia.org

មានសេចក្ដីថា: ព្រះសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់សម្ដែងចំពោះមនុស្សកំឡោះម្នាក់ ឈ្មោះសិង្គាលកៈថា “ការប្រព្រឹត្តផឹកសុរា ហៅថាអបាយមុខមួយយ៉ាង ព្រោះការផឹកសុរានោះជាមេដឹកនាំអ្នកផឹក ឲ្យដល់នូវសេចក្ដីវិនាស ច្រើនយ៉ាង”, ហើយព្រះអង្គត្រាស់សម្ដែងថា: ការប្រព្រឹត្តផឹកសុរានោះនាំឲ្យមានទោសក្នុងលោកិយនេះ ៦ យ៉ាងគឺ

១–សន្ទិដ្ឋិកា ធនជានិ នាំឲ្យវិនាសទ្រព្យសម្បត្តិ ឃើញជាក់ស្តែងក្នុងលោកនេះ ៗ ព្រោះហេតុអ្វី? ព្រោះ ជា ធម្មតាអ្នកផឹកសុរា តែស្រវឹងកាលណាហើយ ក៏រមែង សម្តែងអាការខុសប្រក្រតី គឺជាបើទុកជាខ្លួនក្រីក្រខ្សត់ទ្រព្យ សម្បត្តិ ក៏ធ្វើដូចជាខ្លួនមានទ្រព្យសម្បត្តិច្រើនចាយពុំអស់ ព្រោះសុរានោះ ធ្វើឲ្យចិត្តអ្នកផឹក ឲ្យវិលវល់ ឲ្យយល់ ខុស ឲ្យចិត្តនោះក្លៀវក្លា ហ៊ានចាយវាយឥតបទ ទិញ សុរា និងគ្រឿងស៊ីផ្សេង ៗ ចំពោះខ្លួនឯងផង ចែកដល់ ពួកអ្នកផឹកផងគ្នាផង លែងគិតពីធ្វើការរកស៊ី, គិតតែពី ស៊ីផឹកសប្បាយ ចាយទាល់តែអស់ប្រាក់ពីខ្លួន រួចហ៊ាន ផឹកជឿអ្នកម្ចាស់សុរា រាល់ ៗ ថ្ងៃតទៅទៀត, លុះផឹកជឿ យូរ ៗ ទៅ ជំពាក់គេកាន់តែច្រើនឡើង ៗ ក៏ឥតមានគិតពី

www.elibraryofcambodia.org

ជំពាក់គេ លុះដល់អ្នកម្ចាស់សុរាគេតឹងទារ រកអ្វីសងគេមិនបាន, បើនៅមានរបស់អ្វីក្នុងផ្ទះ ដូច ទូ តុ ចានក្បាន ឬ សំពត់អាវផ្សេងៗ របស់ខ្លួន ឬ របស់ប្រពន្ធកូន ក៏លែងគិត ត្រូវលក់ៗ ត្រូវបញ្ចាំៗ ទាល់តែអស់ ឲ្យតែខាងបានប្រាក់ យកមកសងគេខ្លះ ចាយកាយស៊ីផឹកឲ្យសប្បាយខ្លួនឯងខ្លះ ឥតមានគំនិតគិតស្តាយ ឥតមានញញើតខ្លាចចិត្តប្រពន្ធកូន ឬអាណិតដល់ប្រពន្ធកូនឡើយ ។ អ្នកផឹកសុរា តែផឹកញៀនជាប់ដោះខ្លួនមិនរួចហើយ, កាលបើអស់ទ្រព្យរបស់ក្នុងផ្ទះហើយ ប្រសិនបើនៅមានគោក្របី ឬ ទីដីស្រែចំការចម្ការដំណាំ ក៏ទុកពុំគង់ នឹងយកទៅលក់ ឬ បញ្ចាំ យកប្រាក់មកចាយស៊ីផឹកទាល់តែអស់ពុំខាន ។

ការប្រព្រឹត្តផឹកសុរា រមែងបំផ្លាញអ្នកផឹកឲ្យវិនាស

www.elibraryofcambodia.org

អស់ទ្រព្យ ដែលមានស្រាប់ ហើយបិទផ្លូវទ្រព្យដែលមិនទាន់មាន មិនឲ្យកើតឡើងបាន ព្រោះសុរានោះមិនដែលនាំបណ្ដាលអ្នកផឹក ឲ្យចេះគិតរកស៊ីធ្វើស្រែកាប់ចំការ ឬជួញលក់ដោយមាំមួនបានឡើយ, បើទុកជាអ្នកផឹកនោះចេះរកស៊ីខ្លះ ក៏រកបានបន្តិចបន្តួច គ្រាន់តែបំពេញការផឹកប៉ុណ្ណោះឯង, ម៉្លោះហើយទ្រព្យចាស់ក៏អស់ ទ្រព្យកើតថ្មីក៏គ្មាន ឈ្មោះថាវិនាសធនធានអស់ ។

www.elibraryofcambodia.org

២– កលហប្បវឌ្ឍនី នាំបណ្ដាលឲ្យកើតការឈ្លោះប្រកែក ៗ ព្រោះហេតុអ្វី ? ព្រោះធម្មតាអ្នកផឹកសុរា តែផឹកស្រវឹងកាលណាហើយ រមែងមានចិត្តក្ដៅពុះពោរឡើង នាំមិនឲ្យស្គាល់ខុសត្រូវ តាមតែជួបប្រទះនឹងអ្នកណាក៏ដោយ ឥតមានកោតញញើត ចេះតែនិយាយ

ក្អេងក្អាង រករឿងប្រមាថមើលងាយគេ ដរាបទាល់តែអ្នកដទៃគេអត់ទ្រាំមិនបាន ក៏កើតទៅជាឈ្លោះប្រកែកគ្នា, ជួនកាលមានដល់ទៅវាយដំប្រចំចាក់កាប់សម្លាប់គ្នាក៏មាន ។ អ្នកផឹកស្រា បើឥតមានអ្នកដទៃនឹងឈ្លោះ ក៏រករឿងឈ្លោះនឹងប្រពន្ធកូនរបស់ខ្លួនក្នុងផ្ទះ ឬជនជាញាតិសន្តានជិតខាង មានជួនកាលស្រវឹងឡើង វាយបានឆ្នាំងក្នុងផ្ទះបែកបាក់អស់ទៅក៏មាន ។ បើឥតមានអ្នកណាធ្វើយតបទេ ក៏មិនឈប់ស្ងៀម ចេះតែនិយាយប៉ប៉ាច់ប៉ប៉ោចម្នាក់ឯង ខុសខ្លះត្រូវខ្លះ ដូចជាមនុស្សឆ្កួតសិប់ ។ បើអ្នកផឹកណាមួយ ផឹកស្រវឹងហើយខំសម្ងំឲ្យស្ងៀម មិនរករឿងឈ្លោះប្រកែកឬមិននិយាយឡូឡា ក៏គង់តែមិនរួចពីទោសណាមួយ ដូចមានសម្តែងតទៅក្នុងខាងមុខ ។

www.elibraryofcambodia.org

៣–ភេគាធំ អាយតធំ នាំបណ្ដាលឲ្យកើតរោគផ្សេងៗ មានរោគងងឹតភ្នែកជាដើម ។ ព្រោះហេតុអ្វី? ព្រោះថាសុកនោះ ជាវត្ថុក្ដៅ តែអ្នកផឹកលេបចូលទៅក្នុងខ្លួនហើយ រមែងមានចំហាយផ្សាយ ដាលឡើងមកភាគកាយខាងលើ ធ្វើឲ្យក្ដៅក្នុងភាគកាយខាងលើនោះដោយ

www.elibraryofcambodia.org

ច្រើន នាំបណ្ដាលឲ្យស្រវាំងភ្នែក ហ៊ឹងត្រចៀកជាដើម ជាហេតុនាំឲ្យកើតរោគផ្សេងៗ មានរោគក្នុងភ្នែក ក្នុងត្រចៀក និងក្នុងមាត់ ជាដើម ។ មិនត្រឹមតែប៉ុណ្ណោះឡើយ សុកនេះមានចំហាយធ្វើឲ្យក្ដៅសព្វសព៌ាង្គកាយ អាចឲ្យកម្លាំងដល់គេជាធាតុ ឲ្យមានកម្លាំងក្ដៅជាងប្រក្រតី; ឯរូបរាងកាយរបស់មនុស្សនេះ កាលបើគេជាធាតុមានកម្ដៅស្មើស្រួលល្អ ក៏បានសុខស្រួល កាលបើគេជាធាតុមិនជា

ប្រក្រតី ប្រែត្រឡប់ជាក្តៅខ្លាំងពេក រូបកាយក៏ត្រឡប់ទៅជាពុំសប្បាយ មានជម្ងឺផ្សេងៗ មានគ្រុនក្តៅជាដើម ។ សុរានេះ ជាវត្ថុឲ្យកម្លាំងដល់តេជោធាតុ ក្នុងវេលាដែលអ្នកផឹកលេបចូលទៅ បើយូរៗ ផឹកម្តង គ្រាន់តែមធ្យម បើផឹកជានិច្ច រូបកាយក៏ក្តៅជានិច្ច ម្ល៉ោះហើយនាំឲ្យរូបកាយឆាប់ចាស់ ឆាប់ស្រុតស្រោម ឧបមាដូចដើមឈើខែប្រាំង កាលបើត្រូវកម្តៅព្រះអាទិត្យជានិច្ចហើយ, ក៏រមែងតែរញោមស្រពោន ជ្រុះស្លឹក, ឯរូបកាយនៃមនុស្សយើង ក៏ដូច្នោះដែរ, កាលបើត្រូវកម្តៅជានិច្ចហើយ ក៏រមែងតែឆាប់ចាស់ជរា កើតរោគាផ្សេង ៗ ។

www.elibraryofcambodia.org

សុរានេះ មិនមែនត្រឹមតែនាំឲ្យកើតរោគដែលអាស្រ័យនឹងរូបកាយខាងក្រៅប៉ុណ្ណោះឡើយ វានាំបណ្តាលឲ្យ

កើតកោតខាងក្នុងចិត្តថែមទៀត, កោតក្នុងចិត្តនោះគឺ លោភោ, ទោសោ, មោហោ ជាដើម, កោតនេះកើតឡើងមិនបំផ្លាញរូបកាយខាងក្រៅនេះទេ, កោតនេះ បំផ្លាញឲ្យខូចជាតិមនុស្ស គឺលែងឲ្យបានមកកើតជាមនុស្សទៀត នាំឲ្យទៅកើតក្នុងកំណើតដ៏ទាបថោក ក្នុងអបាយភូមិទាំង ៤ ឯណាមួយ ។

www.elibraryofcambodia.org

៤— អកិត្តិសញ្ញាណនី នាំបណ្ដាលឲ្យខូចកេរ្តិ៍ឈ្មោះ ឲ្យកើតមានពាក្យតំណិះដំណៀល ពាក្យគរហានិន្ទា ដល់ខ្លួនអ្នកផឹកស្រា ។ ព្រោះហេតុអ្វី ? ព្រោះថាធម្មតាអ្នកផឹកស្រាតែស្រវឹងហើយ រមែងសម្ដែងអាការថុកពាខុសពីច្បាប់លោកនិងច្បាប់ធម៌, ទាំងកាយវាចាចិត្ត ក៏ខុសពីប្រក្រតី ញុំាងជនប្រុសស្រីទាំងឡាយដែលគេមានសណ្ដាប់រៀបរយល្អ ឲ្យគេមិនពេញចិត្ត ឲ្យគេធុញទ្រាន់

ក្នុងចិត្ត ឲ្យគេសម្គាល់បានថា ខ្លួនជាមនុស្សអាក្រក់ ឲ្យគេហ៊ានប្រមាថមើលងាយ, ទោះបីមានការអ្វី ដែលគួរគេហៅរក គេក៏មិនហៅរក ដោយគេសម្គាល់ថា ខ្លួនជាមនុស្សអាក្រក់ មនុស្សប្រមឹក ធ្វើការអ្វីក៏មិនកើត និយាយអ្វីក៏មិនបានការ ៗ ដែលនាំឲ្យខូចកេរ្តិ៍ឈ្មោះនោះ មិនមែនត្រឹមតែខ្លួនអ្នកផឹកម្នាក់ឯងឡើយ នាំឲ្យខូចកេរ្តិ៍ឈ្មោះដល់ប្រពន្ធនិងកូនចៅប្រុសស្រីរបស់ខ្លួន តទៅទៀត គឺថាបើកូនចៅប្រុសស្រីណាមួយ មានហេតុអ្វីដែលមិនជាទីគាប់ចិត្តរបស់អ្នកស្រុក គេៈពោលទោសមួយរំពេចថា ពួកអ្នកប្រមឹក សុទ្ធតែបែបហ្នឹងទាំងអស់ ៗ

www.elibraryofcambodia.org

៤- ហិរិកោបិននិទំសនី នាំឲ្យហ៊ានសម្ដែងកេរខ្មាសរបស់ខ្លួនដល់អ្នកឯទៀត ៗ ព្រោះហេតុអ្វី? ព្រោះ

ថា ធម្មតាអ្នកផឹកស្រា តែស្រវឹងហើយ រមែងមានចិត្តគិត ភ្លាត់ខុសប្រក្រតី ឥតមានអៀនខ្មាសអ្នកឯណាមួយឡើយ, ដូចជាសំពត់អាវ ដែលមនុស្សក្នុងលោកគេតែងស្លៀកពាក់ ដើម្បីបិទបាំងគេរខ្មាស អ្នកផឹកស្រាស្រវឹង ត្រឡប់ទៅ ជាមិនរវល់នឹងសំពត់អាវស្លៀកពាក់ តាមតែអ្នកណាគេ

www.elibraryofcambodia.org

ឃើញអ៊ីក៏ដោយ ឥតមានរវល ទាំងអំពើឯណាអាក្រក់ ដែលគេមិនហ៊ានធ្វើដោយកាយ ឬសំដីឯណាជាអសប្បុ-រស ដែលគេមិនហ៊ាននិយាយ អ្នកផឹកស្រាស្រវឹងបេះតែ ហ៊ានធ្វើ ហ៊ាននិយាយ ឥតមានអៀនខ្មាស ។

៦–បញ្ញាយ ទុព្វលីការណី ធ្វើប្រាជ្ញាឲ្យអាប់ ឲ្យអន់ថយចុះ ៗ ព្រោះហេតុអ្វី ? ព្រោះថាស្រារមែងធ្វើចិត្ត អ្នកផឹកឲ្យវិលវល់ មិនឲ្យចិត្តនោះតម្កល់នឹងល្អបានឡើយ

ម្ល៉ោះហើយ រៀនអ្វីក៏មិនចាំ គិតការអ្វីក៏មិនលេច ប្រាជ្ញាចេះតែទន់ថយចុះ ៗ ដ្បិតប្រាជ្ញាដែលនឹងកើតចម្រើនឡើងនោះ ដោយអ្នកណាមួយប្រឹងទប់ចិត្តឲ្យនឹងល្អ ហើយខំគិតពិចារណាហេតុផ្សេង ៗ ឬខំប្រឹងរៀនប្រឹងស្តាប់ ទើបប្រាជ្ញាអាចកើតឡើងបាន ឬនឹងនាំឲ្យប្រាជ្ញាដែលមានតិចកាន់តែមានច្រើនឡើង ៗ អ្នកផឹកសុរាតែស្រវឹងហើយមិនចេះទប់ចិត្តឲ្យនៅនឹងបានទេ រៀនវិជ្ជាអ្វីក៏រៀនមិនកើត ស្តាប់ពាក្យទូន្មានអ្នកណាក៏មិនចេះស្តាប់ ម្ល៉ោះហើយប្រាជ្ញាក៏ចេះតែអន់ថយចុះបន្តិចម្តង ៗ ៗ បើអ្នកផឹកសុរា ចេះតែប្រព្រឹត្តផឹកឲ្យជាប់ជានិច្ចទៅទៀត, ប្រាជ្ញានោះ ចេះតែអន់ថយទៅដរាប ទាល់តែសាបសូន្យអស់រលីងពីខ្លួន ត្រឡប់ទៅជាមនុស្សឥតមានដឹងខុសត្រូវ គឺធ្វើក៏ខុស និយាយក៏

ខុស គិតក៏មិនត្រូវ ស្មើនឹងមនុស្សឆ្កួតសិប់នោះដែរ ព្រោះសុរាជាគ្រឿងបំផ្លាញសតិបញ្ញារបស់អ្នកផឹក ឲ្យមានកម្លាំងថយចុះ ។

សុរានេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា ជាវត្ថុមានពិស អាចបំផ្លាញពួកអ្នកផឹក ឲ្យបាននូវទោសទាំង ៦ ប្រការ ដូចសេចក្ដីដែលបានថ្លែងមកហើយនេះ ។

www.elibraryofcambodia.org

ម្យ៉ាងទៀត ក្នុងគម្ពីរអង្គុត្តរនិកាយ មានពុទ្ធភាសិតសម្ដែងអំពីអបាយមុខ ៤ ប្រការ ដែលជាគ្រឿងបំផ្លាញទ្រព្យសម្បត្តិរបស់ជនានុជនឲ្យវិនាសអស់ទៅ ។

## អបាយមុខ ៤ ប្រការនោះគឺ

១— ឥត្ថីធុត្តោ ជាអ្នកលេងស្រី,

២— សុរាធុត្តោ ជាអ្នកលេងផឹកសុរា,

៣ អក្ខធុត្តោ ជាអ្នកលេងល្បែងភ្នាល់ មានបៀ
ប៉ោជាដើម,

៤ — ចាបមិត្តោ យកមនុស្សខូច មានមនុស្សអ្នក
ស៊ីផឹកនិងអ្នកកាប់ចាក់ជាដើម មកធ្វើជាមិត្តសំឡាញ់ ។

អធិប្បាយថា: ជនប្រុសស្រីណាមួយ ទោះបីមាន
ទ្រព្យសម្បត្តិច្រើនយ៉ាងណាក៏ដោយ តែប្រព្រឹត្តធ្វើខ្លួនឲ្យ
លង់ក្នុងអបាយមុខទាំង ៤ ប្រការនេះណាមួយហើយ គឺ
នឹងវិនាសទ្រព្យសម្បត្តិ ដោយឆាប់រហ័ស ព្រោះអបាយ-
មុខទាំង ៤ ប្រការនេះ ព្រះសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់សម្តែង
ប្រៀបឧបមាថា ដូចជាផ្លូវទឹក ៤ កន្លែង សម្រាប់បង្ហូរទឹក
ចេញពីក្នុងស្រះ ។ សេចក្តីប្រៀបថា ទីស្រះ ១ ក្នុង
រដូវដែលមិនសូវមានទឹកភ្លៀងបរិបូណ៌, ទឹកក្នុងស្រះ ក៏មិន

www.elibraryofcambodia.org

សម្បូណ៌ ហើយថែមទាំងស្រះនោះមានផ្លូវទឹក ៤ កន្លែង សម្រាប់បង្ហូរទឹកចេញពីក្នុងស្រះថែមទៀត, ទឹកនោះ ចេះតែហូរចេញមិនឈប់, ស្រះនោះឯងនឹងរីងស្ងួតដោយឆាប់រហ័ស, បើទុកជាស្រះមានទឹកច្រើនយ៉ាងណាក៏ដោយ តែមានផ្លូវទឹកចេញមិនឈប់ហើយ ស្រះនោះ ក៏គង់តែរីងស្ងួតអស់មិនខាន; ស្រះនោះប្រៀបដូចជាជនប្រុសស្រីទាំង

www.elibraryofcambodia.org

ឡាយក្នុងលោកនេះ, ទឹកក្នុងស្រះប្រៀបដូចទ្រព្យសម្បត្តិ, ឯផ្លូវបង្ហូរទឹកចេញពីស្រះ ប្រៀបដូចអបាយមុខ ៤ សម្រាប់បង្ហូរចេញនូវទ្រព្យសម្បត្តិ, បើទុកជាជនណាមួយ មានទ្រព្យច្រើនយ៉ាងណាក៏ដោយ តែមានអបាយមុខទាំង ៤ ហើយ ទ្រព្យនោះនឹងវិនាសអស់ទៅដោយឆាប់រហ័ស បើទុកជាអបាយមុខមានមិនគ្រប់ទាំង ៤ ក៏ដោយ ឲ្យតែមាន

ខ្លួន ក៏គង់តែយូរៗទៅទ្រព្យនោះនឹងវិនាសអស់មិនខាន ៗ

ព្រះបរមសាស្តា ទ្រង់ត្រាស់សម្តែងថា ការផឹកសុរា នេះ មិនមែននាំបណ្តាលឲ្យមានទោស ក្នុងលោកិយនេះ តែម្យ៉ាងប៉ុណ្ណោះទេ នឹងនាំបណ្តាលឲ្យមានទោសទៅក្នុង បរលោកថែមទៀត ៗ ឯទោសក្នុងបរលោកនោះ គឺជន ដែលប្រព្រឹត្តផឹកសុរា កាលបើទម្លាយអាយុសង្ខារ អំពី លោកនេះទៅ នឹងទៅកើតក្នុងទុគ្គតិភូមិ គឺនរកឬប្រេត ឬមកកើតជាមនុស្ស ៗ នោះ ឆ្កួតលេលា, ដែលកើតជា មនុស្សឆ្កួតលេលានោះមិនតែ ១ ជាតិទេឡើយ ជាច្រើនជាតិ ណាស់ រាប់ដោយរយជាតិ រួចពីឆ្កួត មកកើតជាមនុស្ស សាប់ឥតប្រាជ្ញា រៀនចំណេះវិជ្ជាអ្វីក៏មិនចេះ ជាមនុស្ស ដុនដាបទាបថោក ៗ

www.elibraryofcambodia.org

ហេតុដូចមានខាងលើនេះ ជនប្រុសស្រីទាំងឡាយ មិនគួរយល់ឃើញដោយកាន់ប្រឡំថា "សុរានោះ ជាថ្នាំនាំបំបាត់ភេគ, ជាគ្រឿងនាំឲ្យកើតប្រាជ្ញា, ជាគ្រឿងរែកបំបាត់ទុក្ខព្រួយជាដើម" ដូច្នេះឡើយ, គួរតែពិចារណាឲ្យឃើញច្បាស់ថា "សុរានោះ ដូចជាថ្នាំពិស សម្រាប់បំពុលសត្វលោកឬបំផ្លាញសត្វលោកឲ្យវិនាសទ្រព្យសម្បត្តិ, វិនាសប្រាជ្ញា, វិនាសជាតិ" ។ កាលបើពិចារណាឃើញដូច្នេះហើយ គួរចៀសវាងឲ្យផុត អំពីការផឹកសុរា ទើបជាហេតុនឹងនាំឲ្យបានសេចក្ដីសុខស្រួល និងសេចក្ដីចម្រើនដល់ខ្លួន ។

www.elibraryofcambodia.org

# សេចក្ដីប្រួបប្រួមពីទោសផឹកស្រា

បទព្រហ្មគីតិ ៗ អស់ជនទាំងឡាយអើយ កើតមក ហើយបានជាមនុស្ស គួរឲ្យស្គាល់ត្រូវខុស គួរឲ្យស្គាល់ អាក្រក់ល្អ ៗ គួរកុំ[illegible] ថាជា-ស ទោស ថាជាគុណល្អ គួរឲ្យឃើញតាមការពិត ៗ ឯការផឹកស្រា ព្រះសាស្ដាទ្រង់ពិនិត្យ ឃើញតាំងពីអតីត ថាជាគ្រឿង អបាយមុខ ៗ ឲ្យខូចទ្រព្យសម្បត្តិ ឲ្យខ្ចាយខ្ចាត់សេចក្ដី សុខ ឲ្យបានតែគ្រឿងទុក្ខ នាំឲ្យកើតឈ្លោះប្រកែក ៗ នាំ ឲ្យកើតរោគា តែងពាធាក្នុងដួងក្អែក ជួនកាលរោគនោះ បែក ជាលឲ្យកើតរោគផ្សេង ៗ ។ នាំឲ្យខូចកេរ្តិ៍ឈ្មោះ

www.elibraryofcambodia.org

មិនចំពោះតែម្នាក់ឯង ពលខូចបែកដូចផ្សែង ខូចរហូត ដល់កូនចៅ ។ នាំឲ្យខូចគំនិត ពុំមានគិតដល់អង្គជ្រៅ ហ៊ានបើកបង្ហាញទៅ ដល់ពពួកជនទាំងឡាយ ។ នាំឲ្យខូចប្រាជ្ញា ពិចារណាការសម្លាយ មិនលេចមិនធ្លុះធ្លាយ ប្រាជ្ញាអ័ព្ទអន់ថយចុះ ។ រីឯទោសសុរា តែងផ្តន្ទាទាំងស្រីប្រុស នាំឲ្យបានក្តីទុក្ខ ក្នុងបរលោកថែមទៀតផង ។ ហេតុនេះជនទាំងឡាយ ខំខ្វល់ខ្វាយគិតចាំចង ត្រិះរិះឲ្យម៉ត់ហ្មង ឲ្យឃើញច្បាស់តាមធម៌ពិត ។ ដូចបានថ្លែងចារចង តាមទំនងពុទ្ធភាសិត ជាធម៌ដ៏វិចិត្រ គួរឲ្យគិតឃើញគ្រប់គ្នា ។ ហើយគួរប្រឹងលាកលះ ឲ្យស្រឡះពីសុរា នឹងកើតក្តីសុខា ដល់អាត្មាគ្រប់គ្នាហោង ។

ទោសផឹកសុរា ចប់ដោយសង្ខេប ។

www.elibraryofcambodia.org

www.elibraryofcambodia.org

www.elibraryofcambodia.org

www.elibraryofcambodia.org

ហាងកុម្ពុបណ្ណាគារ
រស្មីកម្ពុជា
លេខ ៦៧ វិថីប៉ាស្ទ័រ ភ្នំពេញ

តម្លៃ ២៛០០

www.elibraryofcambodia.org